**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ: ២៧៦១៣ អយក.ចស**

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩

**ជម្រាបមក**

**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការអនុវត្តម៉ោងបង្រៀននិងរៀនជាប្រក្រតីឡើងវិញ នៅតាមគ្រឹះស្ថានសិក្សាទាំងអស់។

**យោង ៖** លិខិតលេខ ១៩៨០ អយក.បស ចុះថ្ងៃព្រហស្បតិ៍ ៦រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា៖ ថ្ងៃប្រាំងអាកាសធាតុក្ដៅហួតហែងបានកន្លងផុតទៅ ថ្ងៃវស្សាបានចូលមកដល់ ធ្វើឱ្យអាកាសធាតុផ្លាស់ប្ដូរមកជាប្រក្រតីឡើងវិញ។ ដើម្បីឈានទៅអនុវត្តម៉ោងបង្រៀននិងរៀនជាប្រក្រតីឡើងវិញ ក្រសួងសូមធ្វើការណែនាំដល់គ្រប់គ្រឹះស្ថានសិក្សាទាំងអស់ត្រូវអនុវត្តម៉ោងពេលចូលនិងចេញជាធម្មតាវិញដូចខាងក្រោម៖

- ពេលព្រឹក ចូលរៀននៅម៉ោង ៧:០០ ចេញម៉ោង ១១:០០
- ពេលរសៀល ចូលរៀននៅម៉ោង ១៣:០០ ចេញម៉ោង ១៧:០០។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមលោកប្រធានធ្វើការផ្សព្វផ្សាយដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ គ្រឹះស្ថានសិក្សា អាជ្ញាធរដែនដី និងសាធារណៈជនទាំងអស់បានជ្រាប និងចាត់ចែងអនុវត្តប្រកបដោយប្រសិទ្ធភាព។

សូមលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**ចម្លងជូន**
- សាលារាជធានី ខេត្ត
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

**"ដើម្បីជ្រាបជាព័ត៌មាន"**
- កាលប្បវត្តិ-ឯកសារ-នា.បស